# តើ ទំព័រ Splash Pages ជាអ្វី?

## ហើយនិងគុណតម្លៃក្នុងការរារាំង ចំពោះអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទលើកុមារលើបណ្តាញអ៊ីនធឺណិតរបស់ទំព័រទាំងនោះ

### ការពិត

- ទំព័រ Splash pages ត្រូវបានប្រើដើម្បីទាក់ទាញអ្នកប្រើប្រាស់អ៊ីនធឺណិត, បង្ហាញសារ ឬនាំអ្នកប្រើប្រាស់ភ្ជាប់បន្តទៅគេហទំព័រផ្សេងទៀត
- ទំព័រSplash pages ត្រូវបានប្រើប្រាស់ដោយអង្គការមិនមែនរដ្ឋាភិបាល, ក្រុមហ៊ុនឧស្សាហកម្ម និង ស្ថាប័នអនុវត្តច្បាប់នានា
- នៅពេលទំព័រ splash pages ត្រូវបានគេប្រើដើម្បីបញ្ឈប់អ្នកប្រើប្រាស់ពីការចូលមើលប្រធានបទណាមួយនោះ ទំព័រផ្សព្វផ្សាយនឹងត្រូវបានគេចាត់ទុកថាជា ទំព័ររារាំង (Stop Page)

## តើវាដំណើរការយ៉ាងដូចម្តេច?

ទំព័រ (splash page) ជាទំព័រ ឬរូបភាពដែលបង្ហាញនៅលើអេក្រង់ពេញលេញ ឬចំណែកខ្លះនៃអេក្រង់ នៅ ពេលដែលគេហទំព័រជាគោលដៅស្វែងរកដោយអ្នកប្រើប្រាស់ កំពុងតែដំណើរការ។

ទំព័រ Splash pages អាចត្រូវបានប្រើប្រាស់សម្រាប់គ្រប់គោលបំណងទាំងអស់ ដោយសារវាជាវិធីមួយនៃការចុះផ្សាយសារ ឬអត្ថបទក្នុងគេហទំព័រ។ ជានិច្ចជាកាលអ្នកផ្សព្វផ្សាយពាណិជ្ជកម្មប្រើប្រាស់ទំព័រ Splashpages ដើម្បីទាក់ទាញអតិថិជន ឬវាអាចត្រូវបានប្រើប្រាស់ដើម្បីជូនដំណឹងដល់លោកអ្នក ឧទាហរណ៍វាធ្វើឲ្យលោកអ្នកដឹងថាលោកអ្នកបានសរសេរអាសយដ្ឋានគេហទំព័រមិនត្រឹមត្រូវ ឬថាគេហទំព័រនោះ មិនដំណើរការទេ។

ទំព័រ Splash pages ក៏អាចត្រូវបានគេប្រើប្រាស់ដើម្បីរារាំងអ្នកប្រើប្រាស់អ៊ីនធឺណិតមិនឱ្យចូលមើលប្រធានបទណាមួយជាក់លាក់ផងដែរ ឧទាហរណ៍ ទំព័រ splash page អាចបង្ហាញនៅពេលអ្នកណាម្នាក់កំពុងព្យាយាមចូលមើលរូបភាព ឬសម្ភារៈអាសអាភាសកុមារ វានឹងរារាំងមិន ឲ្យបុគ្គលនោះអាចមើលរូបភាព ឬសម្ភារៈអាសអាភាសទាំងនោះបាន ព្រោះថាក្នុងដំណាក់កាលចុងក្រោយនៃយន្តការរារាំងគឺពាក់ព័ន្ធនឹងការចំរាញ់ (Filtering) និងការបង្អាក់ (Blocking)*។




*សម្រាប់ព័ត៌មានបន្ថែមសូមមើលតារាងព័ត៌មាន៖ តើអ្វីជាការចម្រាញ់ (Filtering) និងការបង្អាក់ (Blocking)?

---

## ការបដិសេធន៍មិនឲ្យចូលមើល ឬប្រើប្រាស់រូបភាព និងសម្ភារៈដែលពាក់ព័ន្ធនឹងអំពើរំលោភបំពានផ្លូវភេទកុមារ

ទំព័រ Splash pages ត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនខ្លះ - ដូចជាក្រុមហ៊ុន Microsoft និង Google - នៅក្នុងកម្មវិធីស្រាវជ្រាវរបស់ពួកគេ ដែលជាផ្នែកនៃយន្តការរារាំង ដែលមានបំណងការពារមិនឲ្យអ្នកប្រើប្រាស់អ៊ីនធឺណិត ចូលមើល រូបភាព ឬសម្ភារៈអាសអាភាស កុមារតាមប្រព័ន្ធអ៊ីនធឺណិតដោយចេតនា ឬអចេតនា។ នៅពេលអ្នកណាម្នាក់ព្យាយាមចូលមើលគេហទំព័រដែលត្រូវបានគេស្គាល់ថា មានសម្ភារៈអាសអាភាសកុមារ អ្នកប្រើប្រាស់នឹងត្រូវបានបដិសេធមិនឲ្យចូលមើល។ នៅពេល ទំព័រ splash pages ត្រូវបានគេប្រើ អ្នកប្រើប្រាស់អ៊ីនធឺណិតនឹងត្រូវបានគេភ្ជាប់ទៅនឹងសារបម្រាម( deterrence message )។

ទំព័រ Splash pages អាចមានព័ត៌មានផ្សេងៗគ្នា។ ប្រភេទដែលសាមញ្ញបំផុតរបស់ទំព័រ splash page គឺមានសារ មួយដែលបង្ហាញថា ការប៉ុនប៉ងចូលមើលគេហទំព័រនោះ ត្រូវបានបដិសេធ។ សារនេះត្រូវបានគេហៅថាជា error-message ឬ 404-message ទំព័រ Splash pages អាចមានព័ត៌មានបន្ថែមអំពីមូលហេតុ នៃការហាមប្រាមមិនឲ្យចូលមើល (ដោយមាន ឬគ្មានព័ត៌មានលំអិតអំពីច្បាប់ដែលពាក់ព័ន្ធ)។ ព័ត៌មាននេះ អាចត្រូវបានបំពេញបន្ថែមដោយការចង្អុលបង្ហាញអំពីប្រភពដែលអ្នកប្រើប្រាស់អ៊ីនធឺណិតអាចស្វែងរកជំនួយ ឬយោបល់ប្រសិនបើពួកគេមានការព្រួយបារម្ភអំពីស្ថានភាពអារម្មណ៍ផ្លូវភេទរបស់ពួកគេចំពោះកុមារ។

ទំព័រSplash pages អាចមានការព្រមានឱ្យប្រុងប្រយ័ត្ន ឬសារ ដែលពន្យល់អំពីភាពមិនស្របច្បាប់នៃសកម្មភាពរបស់អ្នកប្រើប្រាស់អ៊ីនធឺណិត ឬរូបភាព និងសម្ភារៈអាសអាភាសដែលកំពុងត្រូវបានស្វែងរកដោយអ្នកប្រើប្រាស់អ៊ីនធឺណិត។ ចំពោះអ្នកប្រើប្រាស់ ដែលមិនយល់ស្របចំពោះការហាមឃាត់ខាងលើ ពេលខ្លះពួកគេនឹងត្រូវបានផ្តល់ឲ្យនូវព័ត៌មានអំពីរបៀបនៃការបញ្ជូនបណ្តឹងតវ៉ាចំពោះការហាមឃាត់ទាំងនោះ។ នៅទីបញ្ចប់ ទំព័រ splash pages ខ្លះ មានព័ត៌មាន និង/ឬ តំណភ្ជាប់នឹងបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ ដើម្បី រាយការណ៍អំពីរូបភាព និងសម្ភារៈអាសអាភាសរបស់កុមារលើបណ្តាញអ៊ីនធឺណិត។

តាមរយៈការផ្តល់ជូនព័ត៌មានបែបនេះ ទំព័រsplash pages អាចជួយបង្កើនចំណេះដឹងអំពីភាពមិនស្របច្បាប់នៃរូបភាព និងសម្ភារៈអាសអាភាសរបស់កុមារនិងសកម្មភាពដែលពាក់ព័ន្ធ។ ព័ត៌មានទាំងនេះក៏អាចជួយបំផុសគំនិតឲ្យមានការភ័យខ្លាចចំពោះការជាប់ពន្ធនាគារនិងបង្ហាញអ្នកប្រើប្រាស់អ៊ីនធឺណិតអំពីប្រភពដែលពួកគេអាចស្វែងរកជំនួយ។ទំព័រ Splash pages ជួយបង្កើនសុវត្ថិភាពក្នុងលំហរអ៊ីនធឺណិត តាមរយៈការអប់រំអ្នកប្រើប្រាស់អំពីយន្តការរាយការណ៍ និងតាមរយៈការបង្ការមិនឲ្យមានការលេចចេញនូវរូបភាព និងសម្ភារៈអាសអាភាសទាំងនោះប្រសិនបើមិនមែនជាឆន្ទៈរបស់អ្នកប្រើប្រាស់ទេនោះ។ ជាចុងក្រោយទំព័រ splash pages គឺធ្វើការ រារាំងអ្នកប្រើប្រាស់អ៊ីនធឺណិតមិនឲ្យចូលមើលឬប្រើប្រាស់ រូបភាព និងសម្ភារៈអាសអាភាសកុមារ។

តារាងព័ត៌មាននេះផលិតដោយអង្គការ ECPAT អន្តរជាតិ។ ឧបត្ថម្ភគាំទ្រសម្រាប់ការបកប្រែភាសា និងការផលិតដោយអង្គការ UNICEF។